# តាម៉ៅ និង កូន ព្រមទាំងសត្វលាមួយក្បាល

## Grandpa Tamao, His Son and Donkey



NHEAN CHAMRONG

ញាណ ចំរុង

វិទ្យាស្ថានអន្តរជាតិនៃកម្ពុជា
International Institute of Cambodia

# វគ្គទី១ តាម៉ៅគិតចង់លក់លា

**Tamao wanted to sell his donkey**

នៅក្នុងភូមិមួយមានតាចាស់ម្នាក់ ឈ្មោះតាម៉ៅ គាត់មានកូនប្រុសមួយ ឈ្មោះគីរីវ័ន្ត និងសត្វលាមួយក្បាលផងដែរ។ ឪពុកនិងកូនមានជីវភាពលំបាកណាស់ ពីព្រោះតាម៉ៅគាត់ជាកម្មករលីសែងអង្ករ។ ក្រៅពីការងារនេះ គាត់នឹកមិនឃើញការងារផ្សេងទៀតទេ។

In a village lived an old man named Tamao. He had a son named Kirivorn and owned a donkey. They live hard lives because Tamao is a rice porter, apart from which he cannot do any other jobs as a livelihood.

ថ្ងៃមួយតាម៉ៅបាននិយាយទៅកាន់កូនរបស់គាត់ថា: គីរីវ័ន្តកូន ពុកមានគំនិតមួយ បើយើងយកលារបស់យើងទៅលក់នៅឯក្រុងយ៉ាងម៉េចដែរកូន? ពីព្រោះលារបស់យើង វាចេះដូចសត្វឆ្កែអញ្ចឹង វាអាចដេកចាំផ្ទះ និងមិនសូវស៊ីច្រើនទេ តើកូនយល់យ៉ាងម៉េចដែរ?

គីរីវ័ន្តឆ្លើយទៅឪពុកវិញថា: គំនិតពុកល្អម៉្យាងដែរ កូនគិតថា លារបស់ពួកយើងយកទៅលក់នៅទីក្រុងអាចលក់បានថ្លៃផងមិនដឹង។ តើពុកគិតទៅពេលណាដែរ?

One day, Tamao said to his son: 'Kirivorn, I have an idea if we can sell our donkey in the city, for our donkey is as clever as is a dog. It can also guard the house and eat less. What do you think?'

'Your idea sounds good,' replied Kirivorn. 'We can sell our donkey in high price in the city, I think. So, when will you go?'







តាម៉ៅឆ្លើយទៅកូនវិញភ្លាមមិនបង្អង់យូរឡើយៈ ឪពុកគិតថា យើងនឹងរៀបចំទៅខានស្អែកពីព្រោះពុកត្រូវទៅប្រាប់កន្លែងអង្ករសិន ថាពុកនិងឡើងទៅក្រុងលក់លាចំនួនច្រើនថ្ងៃទើបមកវិញ។

'I think we will go the day after tomorrow because I have to ask for leave of absence for several days from my workplace,' replied Tamao immediately to his son.





ឪពុក និងកូន គិតគ្នារួចក៏ចូលដេកទៅ លុះព្រឹកឡើង តាម៉ៅទៅប្រាប់កន្លែងគាត់លីអង្គរតាមការគិតពីយប់។ គាត់ក៏ធ្វើដំណើរមកកាន់ផ្ទះរបស់ខ្លួនវិញទាំងញញឹមញញៀមគិតថាខ្លួននឹងអាចលក់លាបានលុយច្រើនមិនខាននៅពេលទៅដល់ទីក្រុងនោះ។

After thinking and planning, they both went to bed. The next morning, Tamao went ahead with his plan, going to his workplace to be granted leave of absence. After that he came back home happily, bearing in mind he would be able to sell his donkey in the city with a colossal amount of money.



ឪពុក និងកូន ក៏នាំគ្នារៀបចំឥវ៉ាន់រួចរាល់អស់ ទើបនាំគ្នាដើរសំដៅទៅរកសត្វលា តាម៉ៅនិយាយទៅកាន់លាថា: លាសម្លាញ់អើយ! ថ្ងៃស្អែកពួកយើងនឹងនាំឯងទៅទីក្រុង ដើម្បីលក់ឯងយកកម្រៃចញ្ចឹមជីវិតហើយ ដូចនេះឯងនឹងអាចរស់នៅទីក្រុង ត្រាន់ជាងនៅទីនេះជាមួយពួកយើងដែលជាគ្រួសារក្រីក្រដែរ។

After packing and preparing everything, they walked toward their donkey. There, Tamao said to his donkey:
'Oh my dear donkey! Tomorrow we will take you to the city to be sold for money to support our living condition. There in the city, you will find your life much better than living here with us as a poor family.'

ចំណែកសត្វលាវិញ វាធ្វើទឹកមុខហាក់បីដូចជាមិនចង់បែកពីម្ចាស់វាឡើយ។ រីឯតាម៉ៅនិយាយចប់ក៏នាំកូនចូលគេង និងអាលក្រោកពីព្រលឹម ដើម្បីធ្វើដំណើរទៅកាន់ទីក្រុង។

To the donkey, through its face, there was seemingly seen unwillingness to separate from his owner at all. After talking to the donkey, Tamao and his son went to bed so early so as to get up early to depart to the city.



# វគ្គទី២ តាម៉ៅបានយកលាទៅលក់នៅទីក្រុង

**Tamao took donkey to be sold in the city**



ស្អែកឡើងពេលព្រលឹមស្រាងៗ ឪពុក និងកូន បាននាំគ្នាចងជើងលាដាក់លើឈើ រួចក៏នាំគ្នាសែងសំដៅទៅរកឡានតាក់ស៊ី ដើម្បីធ្វើដំណើរទៅទីក្រុង។

The next morning, they tied the donkey's legs to a wooden pole and carried it to a taxi to the city.



នៅពេលទៅដល់ចំណតឡានតាក់ស៊ី អ្នកដំណើរដែលជិះនាំគ្នាសើចញឹមៗដោយមិនចេញស្តី តាម៉ៅនឹងកូនក៏នាំគ្នាសើចដាក់ទៅវិញ បញ្ជាក់ថាគាត់មានការរីករាយដែលបានរួមដំណើរជាមួយ។

When they arrived at the taxi station, many passengers smiled without uttering a word and in return, Tamao and his son did the same to mean that he and his son were also happy to travel with them.





តាម៉ៅ និងកូន បានមកដល់ទីក្រុងដូចការគ្រោងទុក។ អ្នកទាំងពីក៏បានលើកលាចុះពីឡាន រួចក៏សែងលានោះចាកចេញទៅ។ គាត់បានដើរទៅរកផ្លូវមួយកន្លែងនៃទីក្រុង ហើយអំពាវនាវលក់លារបស់គាត់: តើលោកអ្នកត្រូវការទិញលាទេ...? លាខ្ញុំឆ្លាតដូចសត្វឆ្កែអញ្ចឹង ចេះដេកចាំផ្ទះបានល្អណាស់ ខ្ញុំលក់មិនថ្លៃទេ។

Tamao and his son arrived in the city as planned. They both put the donkey down the taxi and carried it away.
He was walking through a street in the city, hawking his donkey: 'Is there anyone wanting to buy donkey; my donkey is as clever as is a dog. It can also look after your house. I sell it not in high price.'



រំពេចនោះមានមនុស្សជាច្រើនចេញមកពីផ្ទះរបស់ពួកគេ រួចឈរសើចឡើងរំពងពេញផ្លូវ ខ្លះចង្អុលមកគាត់សើចផង ខ្លះចង្អុលទៅលាផង សើចយកដៃកាន់ពោះ ហាក់បីដូចពួកគាត់ជាអ្នកកំប្លែងទើបចេញមកសម្តែងអញ្ចឹង។ គីរីវ័ន្តបាននិយាយទៅកាន់ឪពុករបស់វាថា: ពុក កូនចុកស្មាណាស់ លានេះវាធ្ងន់ដល់ហើយ រកកន្លែងសម្រាកសិនទៅពុក ។

Suddenly, there were many people coming out of their houses and then laughing loudly and loudly in the street. Some of them pointed to him and some to the donkey, laughing with their arms around their abdomens, considering Tamao and his son as jokers who had just come out for performance. Kirivorn said to his father:
'Daddy, I feel numbness in my shoulder. This donkey is very heavy, so I think we'd better find somewhere to take a rest.'



តាម៉ៅឃើញកូន បែកញើសជោគ
អាវនិងពេញថ្ងាស គាត់អាណិតកូនក៏រក
កន្លែងសម្រាក រួចនិយាយទៅកាន់កូន
វិញថា: គីរីវ័ន្តកូន តើកូនឆ្ងល់ទេ ម៉េចក៏
អ្នកទីក្រុងនាំគ្នាឈរសើចយើងដូច្នេះ?
គីរីវ័ន្តឆ្លើយតបទាំងសំឡេងហត់ថា:
មែនហើយពុក កូនក៏ឆ្ងល់ដែរប្រហែល
អ្នកទីក្រុងមិនដែលឃើញសត្វលាទេដឹង
ឬមួយខោអាវរបស់យើងកខ្វក់ពេកទេ
ដឹង?

Seeing his son in sweat making his cloth wet and running down his forehead, Tamoa felt pity on him so much that he found a place for a few minute break, and then said to his son:

'Kirivorn, do you wonder why the city folk laugh at us?'

'Certainly, Dad. I am actually wondering the city folk may have never seen donkey before or perhap it is because our dress is dirty,' replied Kirivorn exhaustedly.





តាម៉ៅ និងកូននាំគ្នាឱនមើលខោអាវរបស់ខ្លួនរួច និយាយថា:
- យើងខំស្លៀកពាក់ថ្មីៗ ព្រោះដឹងថាឡើងមកទីក្រុង កុំឲ្យអ្នកក្រុងសើច តែពួកគេនៅតែសើចទៀត។ កូនអើយកុំទៅគិតយើងជាអ្នកក្រ មិនអាចដូចគេអ្នកមាននៅទីក្រុងទេកូន តើកូនសែងលាទៅមុខទៀតបានទេ?
គីរីវន្តឆ្លើយតបទៅឪពុកវិញថា:
- បាទពុក រួចកូននឹងប្រឹងសែងម្តងទៀត ក្រែងមានគេចង់ទិញលា យើងនឹងអាលឆាប់បានត្រឡប់ទៅផ្ទះវិញ។

Tamao and his son looked at their own dress and then said: 'we try to wear new dress, for we don't want city folk to laugh at us; now they still do it. Please my dear, don't care about it because we are the poor, different from the rich in the city. Can you continue carrying the donkey?'
'Sure dad. I will try to carry the donkey in case someone wants it and we will be able to go back home very soon,' replied Kirivorn.



គិរីវន្តវាស្ទុះក្រោក រួចលើកឈើសែងលាឈានបានមួយចំហៀង ក៏រអិលជើងអុកគូថទៅដី ពុំតែភឹស រីឯលាវិញក៏អុកគូថទៅដីដូចគ្នា រួចវាស្រែកថ្ងូរឡើង។ តាម៉ៅឃើញកូនទល់ផ្អក ក៏ដាក់ឈើ សែងលាចុះ រត់ទៅរកកូនសួរថា: តើកូនមានត្រូវត្រង់ណាទេ? គិរីវន្តឆ្លើយ: អូយ! ពុកកូនឈឺគូទណាស់ កូនលែងសែងលានេះហើយ។ តាម៉ៅឃើញកូនត្អូញឈឺដូចនេះ គាត់ក៏ដាក់គូទអង្គុយក្បែរកូនដែរទៅ។

Kirivorn rushed to get up and lifted the wooden pole carrying the donkey. Hardly had he taken a step when he slipped on the ground, and so the donkey, moaning of intense pain. Seeing that, Tamao dropped down the wooden pole, and ran toward his son, asking:

'Where do you hurt?'

'Ouch! I feel intense pain in my buttock, dad,' replied Kirivorn. 'I won't carry this donkey any longer.'

Seeing his son moaning of intense pain like that, Tamao sat down near him.



# វគ្គទី៣ តាម៉ៅ និងកូន ឈប់លក់លា

**Tamao and his son stopped selling their donkey**

រំពេចនោះ ស្ត្រីចំណាស់ម្នាក់បានដើរមកជិត ឪពុកកូនទាំងពីរ រួចសួរថា: ឱ! តាអើយ ហេតុអ្វីបានជាចង់លក់លាបែបនេះ? តាម៉ៅឆ្លើយតបវិញថា: បាទបងស្រី ខ្ញុំពីរនាក់ឪពុកកូនមកពីស្រុកឆ្ងាយ ហេតុតែជីវភាពក្រីក្រពេក ទើបសម្រេចចិត្តលក់លាជាទីស្រឡាញ់នេះ តើបងស្រីចង់ទិញលារបស់ខ្ញុំទេ?

All at once, an old woman walked near Tamao and his son, asking: 'Oh Grandpa! Why do you want to sell your donkey?'
'Yes sister,' replied Tamao. 'My son and I come from a remote area. We have decided to sell this lovely donkey because of poverty. Do you want to buy my donkey?'

ស្ត្រីវ័យចំណាស់ ឆ្លើយតបទាំងសើចកក្អឹកថា: ឱម្ចាស់ថ្លៃអើយ! ហេតុអ្វី ក៏តា និងកូនល្ងង់យ៉ាងនេះ នៅទីក្រុងគ្មានអ្នកណាគេចង់ទិញលាទេ។ មិនតែប៉ុណ្ណោះ បើតាចង់លក់លា តាអាចជិះលាបាន ដោយមិនបាច់ចងវាសែងនាំតែធ្ងន់ទេ។ ឱតាអើយ! សត្វលាវាល្ងង់ទៅហើយ ហេតុអ្វីក៏តាល្ងង់ដូចវាដែរ។

The old woman laughed and replied: 'Oh, my goodness! Why are you both so silly? You know no one in the city wants to buy donkey. Also if you want to sell your donkey, why not ride it—instead of carrying it? Oh, poor Grandpa! Donkey is silly; why are you as silly like this?'





តាម៉ៅ និងកូនស្តាប់សំដីរបស់ស្រីចំណាស់នេះចប់។ គាត់នៅស្ងៀមមួយសន្ទុះ គាត់យកដៃទៅអង្អែលក្បាលកូន រួចងាកមុខទៅរកស្ត្រីចំណាស់នោះ និយាយទៅកាន់គាត់វិញថា: ឱ! បងស្រីអើយ ខ្ញុំពិតជាគិតមិនឃើញមែនថា ពួកខ្ញុំអាចជិះលានេះបាន ឥឡូវពួកខ្ញុំគួរតែជិះវាត្រឡប់ទៅផ្ទះរបស់ពួកខ្ញុំវិញ ខ្ញុំឈប់លក់វាហើយ។

Tamao and his son were listening to the old woman without uttering a word. After a while he stroked his son's head before turning his face to the old woman, saying: 'Oh sister, I couldn't think, instead of carrying the donkey, we could ride it. Now we should ride it back home; I won't sell it anymore.'

ស្ត្រីវ័យចំណាស់សើចញ្ញឹមៗរួចនិយាយតបបន្តថា: ឱ! តាអើយ សត្វលារបស់តា វាពិតជាត្រូវរស់នៅជាមួយតា និងកូនតាហើយ វាអាចជួយជាយានជំនិះសម្រាប់តានិងកូនផង និងអាចដាក់របស់ផ្សេងៗទៀតនៅលើខ្នងវាសម្រាប់តាដឹកយកទៅលក់ទៀតផង ប្រសិនជាតាចង់រកប្រាក់ដើម្បីចិញ្ចឹមជីវិត។

The old woman smiled and continued: ‘Oh, poor grandpa! your donkey must live with you and your son: it can be used as a mean of transportation and if you want to earn your living, you can sell things by putting loads on its back.’



តាម៉ៅ និងកូនបាននាំគ្នាស្រាយចំណងលាចេញពីឈើសែង រួចយកដៃទៅអង្អែលក្បាលលា រួចពោលទៅកាន់លារបស់គាត់ថា៖ អាកូនលាសម្លាញ់ចិត្តឪពុក ពុកមិនគួរចងជើងឯងព្យួរឡើយលើ ហើយសែងឯងដូចនេះទេ វាលំបាកទាំងឯង លំបាកទាំងយើង ដែលខំសែងឯងស្ទើរស្លាប់។ ដូចនេះ យើសម្រេចចិត្តឈប់លក់ ឯងហើយពួកយើងនឹងជិះឯងត្រឡប់ទៅផ្ទះវិញ។ ពួកយើងនឹងរករបរផ្សេងទៀតដើម្បីចិញ្ចឹមជីវិត ឈប់មានគំនិតយកឯងលក់ទៀតហើយ។



Tamao with his son untied the donkey from the wooden pole and patted his donkey on its head, saying: 'My dear donkey! I shouldn't have tied and carried you like this. You know not only you, but also we the carrier suffer. Now I stop selling you and we will ride you back home. We will find another way to do as a livelihood .'

រីឯសត្វលាវិញវាស្រែក "........" ហាក់បីដូចជាចង់និយាយទៅកាន់ម្ចាស់វាថា "ឱ ម្ចាស់ខ្ញុំអើយ រៀនឲ្យឆ្លាតខុសពីខ្ញុំបន្តិចទៅ កុំល្ងង់ដូចខ្ញុំពេក បើលោកម្ចាស់គិតឲ្យឆ្លាតជាងនេះតាំងពីផ្ទះមក ខ្ញុំមិនបាច់ចងជើងព្យួរឡើងដូចជ្រូកទេ ខ្ញុំត្រូវដើរយ៉ាងស្រួល ហើយក៏មិនបាច់ពិបាកសែងខ្ញុំនាំហត់ដែរ"។

As for the donkey, it shouted '....................' as if it wanted to say to his owner: 'Oh, my poor raiser! Learn to be smarter than this. Don't be as silly as I am. If you had so far been smart, I wouldn't have been tied like a pig, I would have walked easily as normal, so I wouldn't have caused you suffer from carrying me exhaustedly.'





ឪពុកកូនល្ងង់ទាំងពីរនាក់បានអរគុណស្ត្រីវ័យចំណាស់នោះ រួចក៏ឡើងជិះសត្វលារបស់ខ្លួនធ្វើដំណើរបកក្រោយ ដើម្បីត្រឡប់ទៅផ្ទះវិញ។ ក្រឡេកមើលតាមផ្ទះនីមួយៗតាមដងផ្លូវមនុស្សម្នានាំគ្នាស្រែកឡើងម្នាក់មួយម៉ាត់ថា: តាំងតែពីយូរម៉េចឪពុកកូនមិនព្រមជិះលា បែរជានាំគ្នាសែងលា ពិតជាល្ងង់ដូចសត្វលារបស់គាត់អញ្ចឹងហាសៗៗ។

The two silly father and son said thank you to the old woman before they rode their donkey back home. On the way, they heard people from every house along the street yelling out: 'They should have ridden the donkey, rather than carrying it; they are really as sill as is the donkey, Ha! Ha!'

គិរីវ័ន្តនិយាយទៅកាន់ឪពុកថា: ពុកតាមពិតគេនាំគ្នាសើចយើង ព្រោះគេយល់ថាយើងទាំងពីរល្ងង់ដូចសត្វលាទេតើ។ តាម៉ៅតបទៅកូនវិញថា: ត្រូវហើយកូន ដូចនេះពេលយើងត្រឡប់ទៅផ្ទះវិញមុននឹងគិតធ្វើអ្វីមួយកុំឲ្យល្ងង់ដូចសត្វលាទៀត។

Kirivorn said to his father:
'Dad, they have indeed laughed at us because they have thought we are as silly as is a donkey.'
'That's right, son,' replied Tamao. 'So, after arriving home, we have to think carefully before we do something so that we are not as silly anymore.'

ចាប់ពីពេលនោះមកឪពុកកូនល្ងង់ទាំងពីរនាក់ ព្រមទាំងលាមួយក្បាលនោះ ក្រោយពីបានត្រឡប់មកផ្ទះវិញនាំគ្នាធ្វើកន្ទេលលក់យកកម្រៃសម្រាប់ចិញ្ចឹមជីវិត ដោយដាក់កន្ទេលលើខ្នងលា លក់ជិតៗភូមិរបស់គាត់។ ដូចនេះតាម៉ៅនិងកូន លែងល្ងង់ទៀតហើយ ពេលគាត់ចង់ទៅលក់កន្ទេលនៅទីឆ្ងាយ គាត់តែងតែជិះលារបស់គាត់ធ្វើជាយានជំនិះ។

Since then, the silly father and son as well as their donkey made mats for their livings. They put their mats on the donkey' back for sale in the nearby villages. To do that, Tamao and his son were not silly anymore. When they wanted to sell their mats in distance villages, they used their donkey as a mean of transportation.



ចប់

The End